(ថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ2022)
クメール語

厚生労働省 Ministry of Health, Labour and Welfare

# ចំពោះកុមារអាយុ 5-11 ឆ្នាំ

# សេចក្តីជូនដំណឹងអំពីការចាក់វ៉ាក់សាំងការពារកូវីដ-19

## ហេតុអ្វីត្រូវចាក់វ៉ាក់សាំងកូវីដ?



បើមេរោគកូវីដចូលក្នុងខ្លួនមនុស្ស ហើយគ្នាវាកើនឡើងច្រើន វានឹងធ្វើឲ្យ ក្តៅខ្លួន អស់កម្លាំង ក្អក ពិបាកដកដង្ហើម ឈឺក្បាល ប្រែប្រួលការភ្លក់ជីងរសជាតិជាដើម ហើយនឹងធ្វើឲ្យមិនស្រួលខ្លួន។

បើចាក់វ៉ាក់សាំង ខ្លួនយើងនឹងអាចត្រៀមខ្លួនវាយជាមួយមេរោគកូវីដ ដូច្នេះ ទោះមេរោគឆ្លងចូលក្នុងខ្លួនក៏ដោយ ក៏មិនងាយធ្វើឲ្យទៅជាមិនស្រួលខ្លួនដែរ។

## ពេលចាក់វ៉ាក់សាំងកូវីដ តើគួរតែប្រយ័ត្ននឹងអ្វីខ្លះ?

| | |
|---|---|
| មុន ចាក់ | បើក្តៅខ្លួនចាប់ពី 37.5℃ ឡើងទៅ ឬបើមិនស្រួលខ្លួន គឺមិនអាចចាក់បានទេ ដូច្នេះសូមប្រាប់អ្នកផ្ទះ។ |
| ពេល ចាក់ | វ៉ាក់សាំងនេះគឺចាក់នៅក្បែរស្មា។ សូមទៅចាក់ដោយពាក់អាវដែលងាយស្រួលលាត់ចេញស្មា។ |
| ក្រោយ ចាក់ រួច | ◎ក្រោយចាក់វ៉ាក់សាំងរួច សូមអង្គុយចាំអោយបាន 15នាទីឡើងទៅ ដើម្បីតាមដានអាការៈផ្សេងៗ។ (ពេលខ្លះក៏អាចដល់ទៅ ៣០នាទីផងដែរ)<br>◎នៅថ្ងៃចាក់ អាចធ្វើសកម្មភាពដូចធម្មតាបាន ដូចជាងូតទឹកជាដើម ប៉ុន្តែសូមកុំហាត់ប្រាណខ្លាំង។<br>◎នៅពេលចាក់វ៉ាក់សាំង អាចនឹងចេញអាការៈមិនស្រួលខ្លួនដូចខាងក្រោម ប៉ុន្តែគេរកឃើញថាវានឹងបាត់ទៅវិញដោយខ្លួនឯងក្នុងពេល2–3ថ្ងៃ។<br>○ក្តៅខ្លួន ○មិនស្រួលខ្លួន<br>○អស់កម្លាំង ○រាក<br>○ឈឺក្បាល ○រងាមិនស្រួលខ្លួន |











## បើមានអាការៈមិនស្រួលដូចខាងក្រោមនេះ សូមប្រាប់អ្នកផ្ទះឬមនុស្សធំដែលនៅជុំវិញ។

### ●ពេលចាក់ហើយភ្លាម

○រមាស់ខ្លួន
○ក្អក



### ●នៅថ្ងៃចាក់ឬរយៈពេលប្រហែល4ថ្ងៃក្រោយចាក់ហើយ

○ក្តៅខ្លួន ○ឈឺក្បាល ○ឈឺទ្រូង ○ពិបាកដកដង្ហើម
○អស់កម្លាំង ○រងាមិនស្រួលខ្លួន ○ក្នុងទ្រូងឌុកខាក់ៗ



## សូមចាក់វ៉ាក់សាំងនេះ 2លើក ដោយទុកគម្លាត 3 សប្តាហ៍។

## រឿងសំខាន់ដែលចង់ឲ្យប្អូនៗធ្វើ។

មនុស្សមានផ្សេងៗគ្នា អ្នកខ្លះបានទទួលការចាក់វ៉ាក់សាំងបានលឿន ចំណែកអ្នកខ្លះក៏មានមូលហេតុផ្សេងៗដែលមិនអាចចាក់វ៉ាក់សាំងបានជាដើម។ សូមកុំយកហេតុផលនេះ ជាមូលហេតុក្នុងការនិយាយអាក្រក់ ឬធ្វើបាបអ្នកនៅជុំវិញជាដាច់ខាត។

